ព្រឹត្តិបត្រ

លេខ ០១ ឆ្នាំទី ០១ – ខែមករា គ.ស. ២០០៤ – ព.ស. ២៥៤៧

# កម្ពុជាក្រោម

***Kampuchea Krom***, January, 2004

*ព្រឹត្តិបត្របោះពុម្ពផ្សាយជារៀងរាល់ខែ ដោយសហព័ន្ធខ្មែរកម្ពុជាក្រោម – **KKF's monthly Newsletter***

## អត្ថបទខាងក្នុង

*–សូមស្វាគមន៍.................................៣*

*–ដំណឹងពីអង្គការ UNPO...........៤*

*–មេដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោម ជួបពិភាក្សាជាមួយមេដឹកនាំ ទីម័រខាងកើត និងមេដឹកនាំរណសិរ្ស ទាមទារឯករាជ្យកោះ ម៉ាលិកា* (South Mo–locus)*.................................៤*

*–មេដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោម ចូលរួមពិធីបុណ្យខួបលើកទី ៥០ ទិវាបង្កើតសភា ប្រឹក្សាកិច្ចការអន្តរជាតិនៃក្រុង* Los Angeles*.................៥*

*–ខ្មែរក្រោមនៅភ្នំពេញ ប្រារព្ធពិធីសិទ្ធិមនុស្សលើកទី ៤ ជាប្រវត្តិសាស្ត្រ....៦*

*–វត្តសំរោងឯក ...............................៧*

*–កំណាព្យ ទំនួញព្រះត្រពាំង........១០*

*–រឿងដ៏ខ្លោចផ្សា នៃជនជាតិខ្មែរ–ក្រោម .............................................១១*

*–ជីវប្រវត្តិ ព្រះវីរៈធម្មាចារ្យ មហា សឺន ថាន ..............................................១៤*

## សហព័ន្ធខ្មែរកម្ពុជាក្រោម អបអរសាទររដ្ឋាភិបាល ប៊ូសហ៍ ក្នុងឱកាសចាប់បាន សាដាម ហ៊ូសេន




*មេដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងអង្គសន្និបាទ យូអិនភីអូ លើកទី ៦ – ០៦/១២/២០០១*

លោក សឺន ទូន ប្រធានប្រតិបត្តិ សហព័ន្ធខ្មែរកម្ពុជាក្រោម បានផ្ញើសារលិខិតមួយឆ្ពោះតម្រង់ទៅ សេតវិមាន កាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០៣ ក្នុងឱកាសទ័ពពិសេសរបស់សហរដ្ឋអាមេរិក ប្រមាញ់ចាប់បានមេដឹកនាំផ្តាច់ការ ប្រល័យពូជសាសន៍ សាដាម ហ៊ូសេន ។

ក្នុងនាមសហព័ន្ធខ្មែរកម្ពុជាក្រោម លោក សឺន ទូន បានសម្តែងនូវការកោតសរសើរ និង អបអរសាទរជាអតិបរមា ចំពោះជោគជ័យដែលសហរដ្ឋអាមេរិកសម្រេចបាន នៅក្នុងប្រទេសអៀ–រ៉ាក់ ។ លោកគូសបញ្ជាក់ថា ៖ *ជោគជ័យរបស់សហរដ្ឋអាមេរិកដែលចាប់បានជនផ្តាច់ការដូចរូប សាដាម ហ៊ូសេន មកឲ្យប្រឈមមុខនឹងតុលាការកាត់ទោស ទោះបីធ្វើតាមលំនាំ អៀរ៉ាក់ ឬលំនាំអន្តរជាតិក្តី ក៏នេះជាគំរូដ៏ប្រសើរសម្រាប់ពិភពលោកទាំងមូល ។*

ក្នុងស្ថានភាពខ្មែរកម្ពុជាក្រោម ក៏ធ្លាប់ជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ប្រព្រឹត្តិឡើងដោយរដ្ឋាភិបាលវៀតណាមគ្រប់សម័យកាល លោក សឺន ទូន ក៏បានស្នើឲ្យរដ្ឋាភិបាលសហរដ្ឋអាមេរិក ចាប់ផ្ដើមបើកការស៊ើបអង្កេតថ្នាក់អន្តរជាតិមួយ អំពីទោសប្រល័យពូជ-សាសន៍ ទន្ទឹមនឹងការស៊ើបអង្កេតទោសប្រល័យពូជ-សាសន៍របស់សាដាម ហ៊ូសេន ដែលបានធ្វើឡើងចំពោះជនជាតិឃើត នៅភាគខាងជើងប្រទេសអៀរ៉ាក់ និងក្រុមសម្ព័ន្ធកាន់សាសនាអ៊ីស្លាម និកាយសាអ៊ីត នៅភាគខាងត្បូងនៃប្រទេសនេះ ។ លោកបានស្នើឲ្យមានការស៊ើបអង្កេតករណីប្រល័យពូជសាសន៍ ដែលមេដឹកនាំកុម្មុយ-និស្តយួនបានប្រព្រឹត្តិឡើងចំពោះខ្មែរកម្ពុជាក្រោម ដែលមាន ៤ ចំណុចដូចតទៅ ៖

១-ធ្វើការស៊ើបអង្កេតទោស ប្រល័យពូជសាសន៍ខ្មែរក្រោម ពីអំឡុងឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩ នៅតាមខេត្តទាំងអស់នៃដែនដីសណ្ដទន្លេមេគង្គ ព្រមទាំងខ្មែរ-ក្រោម នៅខេត្តមាត់ជ្រូកទាំងមូលត្រូវរដ្ឋយួនបង្ខំឲ្យចាកចោលភូមិស្រុក និងទ្រព្យសម្បត្តិរបស់ពួកគាត់ត្រូវរឹបអូសយកទាំងអស់ក្នុងឆ្នាំ ១៩៧៨ ។

២-ធ្វើការស៊ើបអង្កេតទោស ប្រល័យពូជសាសន៍ខ្មែរក្រោម ពីអំឡុងឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩២ ក្នុងរយៈកាល ដែលពួកទ័ពយួនកុម្មុយនិស្តកំពុងកាន់កាប់ត្រួតត្រាប្រទេសកម្ពុជា ។

៣-ធ្វើការស៊ើបអង្កេតទោស ប្រល័យពូជសាសន៍ចំពោះករណីព្រះតេជគុណ គឹម តុកចើង និងព្រះសង្ឃខ្មែរក្រោមជាច្រើនអង្គទៀត ព្រមទាំងពលរដ្ឋខ្មែរក្រោមរាប់ពាន់នាក់ ពីអំឡុងឆ្នាំ ១៩៨៤ ដល់ឆ្នាំ ១៩៩០ នៅខេត្តព្រះត្រពាំង និងខេត្តឡុងហោ ។

៤-ធ្វើការស៊ើបអង្កេតទោស ប្រល័យពូជសាសន៍ខ្មែរក្រោម ចំពោះករណីព្រះតេជគុណ ឡឹម យេន ក្នុងខែកក្កដា ឆ្នាំ ២០០២ នៅវត្តទឹកល្អក់ ខេត្តព្រៃកប្បស្សី ។

សូមរំឭកថា មេដឹកនាំកុម្មុយនិស្តយួនធ្លាប់ប្រឆាំងជំទាស់មួយដងរួចមកហើយ ចំពោះជំហររបស់សហរដ្ឋ-អាមេរិក ក្នុងការប្រឆាំងភេរវកម្មនៅ Afghanistan ។ ពេលដែលសង្គ្រាមរវាងសម្ព័ន្ធមិត្ត មានសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងប្រទេសអេស្ប៉ាញ ដឹកនាំដោយរដ្ឋាភិបាលប៊ូសហ៍ និងមេដឹកនាំផ្ដាច់ការប្រល័យពូជ-សាសន៍ នៅអៀរ៉ាក់ផ្ទុះឡើង យួនជានិច្ចកាលថ្កោលទោសសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្ត ។

គេរៀបចំក្បួនបាតុកម្មជាច្រើន ពីទីក្រុងហាណូយ រហូតដល់ព្រៃនគរ កាលពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០០៣ ក្នុងគោលបំណងប្រឆាំងសហរដ្ឋអាមេរិក ដែលគេចោទថារំលោភបំពាន បូរណភាពទឹកដីអៀរ៉ាក់ ដែលជាសម្ព័ន្ធមិត្តរបស់គេពីយូរលង់ណាស់មកហើយ ។

តាមប្រភពព័ត៌មានពីកាសែត Thời Báo kinh tế កាលពីថ្ងៃទី ១២ ខែមករា ឆ្នាំ ២០០២ គណៈប្រតិភូធនា-គារអៀរ៉ាក់ ដឹកនាំដោយលោក Issam Rasheed Huweih បានធ្វើទស្សនៈកិច្ចនៅប្រទេសវៀតណាម ហើយបានពិភាក្សា អំពីការទូទាត់ជាមួយធនាគារពាណិជ្ជកម្មក្រៅប្រទេសវៀតណាម (Vietcombank) ។ ប្រភពដដែលនេះបានឲ្យដឹងថា មកដល់ថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០០១ ទំនិញនាំចេញពីវៀតណាមទៅអៀរ៉ាក់មានតម្លៃ ៥៥,០០៤,០០០ ដុល្លារ ក្នុងនោះការនាំចេញអង្ករមានតម្លៃ ៤១,៦៨៣,០០០ ដុល្លារ ។ បានសឲ្យឃើញទំនាក់-ទំនងដ៏ស្អិតរមួត រវាងមេដឹកនាំផ្ដាច់ការ ប្រល័យពូជ-សាសន៍នៃប្រទេសទាំងពីរនេះ ៕ ***VOKK***


និពន្ធនាយក ៖ **ថាច់ ខ៉ុក ថាច់**

អ្នកនិពន្ធ ៖ **ទ្រឹង ភូនាន់, តាំង សារៈ, ថាច់ សុមេធ, លី ឈួន**

ជំនួយការបច្ចេកទេស ៖ **ដេខង ថាច់**

ការិយាល័យទំនាក់ទំនង និងចែកផ្សាយ ៖

Worcester, MA 01613, USA
P.O. Box 2569, Tel: (508) 922-4834

E-mail: newsletter@khmerkrom.net

ការបោះពុម្ពបែប PDF មាននៅក្នុងគេហទំព័រ www.khmerkrom.net

# សូមស្វាគមន៍

ព្រឹត្តិបត្រ **កម្ពុជាក្រោម** បោះពុម្ពផ្សាយដោយសហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងគោលបំណង ជម្រាបជូនបងប្អូនជនរួមឈាម និង មិត្តអ្នកអានជាទីមេត្រីអំពីទស្ស–នៈវិស័យ គោលនយោបាយ សកម្មភាព និង ព្រឹត្តិការណ៍ជុំវិញពិភពលោក ដែលទាក់ទងនឹងខ្មែរកម្ពុជាក្រោម ។

ដូចបានប្រកាសជូនស្រាប់ នូវសារលិខិតដែលអង្គការយូអិនភីអូ បានផ្ញើជូននាយករដ្ឋមន្ត្រីយួន ឲ្យពិនិត្យឡើងវិញជាបន្ទាន់នូវសោកនាដកម្មធំៗ ចំនួន ៦ បែប ដែលខ្មែរក្រោមកំពុងរងគ្រោះ ៖

១–ប្រវត្តិសាស្ត្រខ្មែរក្រោម ដែលត្រូវបានកែប្រែ និងមានផែនការណ៍ច្នៃឡើងវិញ ។

២–ធនធានសេដ្ឋកិច្ច ត្រូវបានរឹបអូសយក ព្រមទាំងមិនបានទទួលផលប្រយោជន៍ទាល់តែសោះ ។

៣–ភាសា វប្បធម៌ សាសនា ត្រូវបានលុបបំបាត់ និងកែប្រែឲ្យខុសពីសារធាតុដើម ។

៤–ចំនួនប្រជាជនត្រូវបានរំលាយ ដោយបំបាត់គ្រប់មធ្យោបាយ និងការជន្លៀសដោយបង្ខំ ។

៥–មិនបានទទួលជំនួយអន្តរជាតិ ។

៦–បដិសេធមិនឲ្យទទួលនូវសិទ្ធិ និងសេរីភាពទាំងឡាយ ដែលបានចែងក្នុងច្បាប់អន្តរជាតិ ។

ដើម្បីដោះស្រាយនូវបញ្ហាខាងលើ លុះត្រាណារដ្ឋាភិបាលសង្គមនិយមវៀតណាម ទទួលយកនូវលក្ខ–ខ័ណ្ឌទាំងពីរខាងក្រោម ៖

១–ត្រូវបញ្ចប់ការធ្វើអាណានិគម លើទឹកដីកម្ពុជាក្រោម ដែលជាមាតុភូមិរបស់ខ្មែរក្រោម ។

២–ត្រូវដាក់ដែនដីនេះ នៅក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ យោងតាមធម្មនុញ្ញ នៃអង្គ–ការសហប្រជាជាតិ ជំពូកទី ១១ ទី ១២ និង ទី ១៣ ដើម្បីឲ្យខ្មែរក្រោម មានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង និងមានសិទ្ធិសេរីភាពពេញបរិបូណ៌ ។

សហព័ន្ធមានសោមនស្សរីករាយ រង់ចាំទទួលនូវយោបល់ពីគ្រប់មជ្ឈដ្ឋាន ដើម្បីឲ្យព្រឹត្តិបត្រនេះកាន់តែប្រសើរឡើង ហើយមានខ្លឹមសារ និងមានអត្ថប្រយោជន៍ចំពោះជាតិយើង ។ ដោយឡែកក្នុងគោលបំណងរក្សាអក្សរសាស្ត្រខ្មែរ ឲ្យបានគង់វង្សតរៀងទៅ ។ យើងខ្ញុំមានសង្ឃឹមថា លោកអ្នកមិត្តអ្នកអាន នឹងបានយល់ដឹងនូវគោលជំហររបស់សហព័ន្ធ និងគាំទ្រព្រឹត្តិបត្រនេះឲ្យបានដំណើរការល្អ ។

ដោយគោរពពីខ្ញុំបាទ

**ថាច់ ង៉ុក ថាច់**

**ព្រឹត្តិបត្រ កម្ពុជាក្រោម**

**ជូនពរ ឆ្នាំថ្មី**

**ឆ្នាំ គ.ស. ២០០៤**

# ដំណឹងពីអង្គការ UNPO

*-អង្គការ UNPO ទទួលបានសមាជិកថ្មី ៣ ទៀតហើយ*

*-សហព័ន្ធខ្មែរកម្ពុជាក្រោមសម្តែងការរីករាយនិងស្វាគមន៍ប្រជាជាតិ Montagnard ដែលបានចូលជាសមាជិក UNPO*

កាលពីថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៣ អង្គការ UNPO បានធ្វើរបាយការណ៍បូកសរុប អំពីសកម្មភាពរបស់អង្គការនេះ ដោយមានខ្លឹមសារសង្ខេបដូចជា ស្តីអំពីការតែងតាំងលោក ប៊ូស្តាគិន ឲ្យធ្វើជាអគ្គលេខាធិការស្តីទីរបស់អង្គការ UNPO ជំនួសលោក អែគិន អាលតាគិន ។ ហើយតែងតាំងលោក អែគិន អាលតាគិន ឲ្យឡើងទៅជាអនុប្រធាននៃគណៈកម្មាធិការអចិន្ត្រៃយ៍ នៃអង្គការ UNPO ទៅវិញ ។

នៅក្នុងរបាយការណ៍នេះដែរ អង្គការ UNPO បានរំឭកឡើងយ៉ាងច្រើនដង អំពីសហព័ន្ធខ្មែរកម្ពុជាក្រោម ជាពិសេសការចូលរួមយ៉ាងសកម្មរបស់សហព័ន្ធ ជាមួយនឹងសកម្មភាពនានាដ៏សំខាន់ ៗ នៃអង្គការនេះ ជាពិសេសជាងនេះទៅទៀតគឺ អង្គការ UNPO បានសង្កេតឃើញពលរដ្ឋខ្មែរក្រោមមានស្មារតីខ្ពស់ ចំពោះវាសនាអនាគតរបស់ពួកគេ ។ ខ្មែរក្រោមអាចកាន់កាប់វាសនាខ្លួនដោយខ្លួនគេបានយ៉ាងមាំទាំ ដូចសមាជិកឯទៀតរបស់ អង្គការ UNPO ដែលទើបទទួលបានឯករាជ្យអញ្ចឹងដែរ ប្រសិនជាមានឱកាសល្អជូនឲ្យពួកគេ ។

របាយការណ៍បានបញ្ជាក់ទៀតថា អង្គការ UNPO បានសម្រេចចិត្តទទួលស្គាល់ឲ្យមានប្រជាជាតិថ្មី ៣ ទៀតឲ្យចូលជាសមាជិក ។ សមាជិកទី ១ គឺប្រជាជាតិ ហ្វាវែនដា(Hvavenda) នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ប្រជាជាតិនេះត្រូវបាត់ឯករាជ្យក្នុងឆ្នាំ ១៨៩៨ ។ សមាជិកទី ២ គឺប្រជាជាតិ មង់តាញ្ញា (Montagnard) នៅភូមិភាគវៀតណាមកណ្តាលបច្ចុប្បន្ន ដែលខ្មែរធ្លាប់ស្គាល់តាមរយៈចលនា FULRO ជាអ្នកភូមិផងរបងជាមួយ និងមិត្តរួមទុក្ខរបស់ខ្មែរក្រោម ដែលត្រូវជនជាតិយួនធ្វើការទន្ទ្រានឈ្លានពានជិះជាន់ បោកបញ្ឆោត ដូចខ្មែរក្រោមដែរនោះ។ រដ្ឋអំណាចយួនសេរី បានទទួលស្គាល់ឲ្យស្វ័យភាពដល់ប្រជាជាតិមង់តាញ្ញា ក្នុងកិច្ចព្រមព្រៀងមួយ ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ ១៩៦៧ តែពុំបានគោរពទេ ។ សមាជិកថ្មីទី ៣ គឺប្រជាជាតិ អាវ៉ាស៊ី (Ahwazi) ជាជនជាតិអារ៉ាប់នៅក្នុងខេត្ត ឃុយេស្ថាន (Khuzestan) នៃប្រទេសអៀរ៉ង់បច្ចុប្បន្ន ។ ធ្លាប់មានស្វ័យភាពក្នុងប្រទេសអៀរ៉ង់រហូតដល់ឆ្នាំ ១៩២៥ ។

សហព័ន្ធខ្មែរកម្ពុជាក្រោម ស្វាគមន៍ចំពោះប្រជាជាតិទាំងបី ដែលបានអង្គការ UNPO ទទួលស្គាល់ជាសមាជិក កាលពីថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៣ ។ លោក សឺន ទូន ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម បានសម្តែងការរីករាយ និងស្វាគមន៍ចំពោះ ប្រជាជាតិទាំងបីជាពិសេសគឺ ប្រជាជាតិមង់តាញ្ញា ឬកុលសម្ព័ន្ធភ្នំ ដែលបានអង្គការ UNPO សម្រេចចិត្តទទួលស្គាល់ជាសមាជិក ។ លោក កុក សរ ប្រធានប្រជាជាតិ មង់តាញ្ញា សូមថ្លែងអំណរគុណដល់សហព័ន្ធខ្មែរកម្ពុជាក្រោម និង សូមជូនពរឲ្យខ្មែរក្រោមបានសម្រេចអ្វី ៗ ទាំងអស់ដូចក្តីប្រាថ្នាក្នុងឆ្នាំ ២០០៤ ខាងមុខនេះ ៕ *ទ្រីវ ភូនាន់*

# មេដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោម ជួបពិភាក្សាជាមួយមេដឹកនាំ ទីម័រខាងកើត និងមេដឹកនាំរណសិរ្ស ទាមទារឯករាជ្យកោះ ម៉ាលិកា (South Molocus)

កាលពីថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០០៣ នៅសកលវិទ្យាល័យ UCLA បានរៀបចំឲ្យមានកម្មវិធីសន្ទនាមួយ ជាមួយលោក ផែណាន់ដូរ ឡាសាម៉ា ដេអារ៉ាវយោ (Fernando La Sama De Raujo) ប្រធានគណបក្សប្រជាធិបតេយ្យ ដែលជាគណបក្សធំទី ២ និងជាសមាជិករដ្ឋសភាប្រទេសទីម័រខាងកើត ។

លោក សឺន ទូន ប្រធានប្រតិបត្តិ សហព័ន្ធខ្មែរកម្ពុជាក្រោម និង លោក ខែលរិន លី ជាប្រធាននាយកដ្ឋានវែបសាយនៃសហព័ន្ធ ត្រូវបានគេអញ្ជើញឲ្យចូលរួមក្នុងកម្មវិធីនេះ ។ ការពិភាក្សានៅជុំវិញប្រធានបទថា ធ្វើ

យ៉ាងណា ឲ្យការកសាងប្រទេសទីម័រថ្មី បានឿនលឿន ហើយកុំឲ្យជំពាក់បំណុលបរទេសច្រើនពេក ។ លោកបាន បញ្ជាក់ថា រដ្ឋធម្មនុញ្ញរបស់ប្រទេសទីម័រ មានបញ្ជាក់ថា *«ប្រទេសនេះគាំទ្រដល់ប្រជាជាតិ ដែលត្រូវគេជិះជាន់ ដើម្បីរើបម្រះពីការជិះជាន់»* ។

រួមក្នុងពេលនេះដែរ មេដឹកនាំសហព័ន្ធ បានជួប ពិភាក្សាជាមួយតំណាងរបស់ រណសិរ្ស ទាមទារឯករាជ្យ កោះម៉ាលិកា (South Molocus) គឺលោក ហែមមី វ៉ាតទី មេណា (Helmi Wattamena) ស្តីអំពីបញ្ហារបស់ខ្មែរ កម្ពុជាក្រោម នៅក្រោមការជិះជាន់របស់យួន ។ សូម បញ្ជាក់ថា កោះម៉ាលិកា ជាសមាជិកមួយរបស់អង្គការ UNPO និង ប្រទេសទីម័រខាងកើត មុនពេលឯករាជ្យមួយ ឆ្នាំកន្លងហើយនោះ ក៏ជាសមាជិកមួយ របស់អង្គការ UNPO ផងដែរ ៕

*ទ្រីរ ភូនាន់*



*រូបថត លោក សឺន ទូន និង លោក ខែលវិន ជាមួយមេដឹកនាំទីម័រខាងកើត និង មេដឹកនាំកោះ ម៉ាលិកា*

# មេដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោម ចូលរួមពិធីបុណ្យខួបលើកទី ៥០ ទិវា បង្កើតសភាប្រឹក្សាកិច្ចការអន្តរជាតិ នៃក្រុង Los Angeles

កាលពីថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០០៣ នៅក្រុង លោស អាំងជើឡែត (Los Angeles) មានរៀបចំពិធីបុណ្យខួប លើកទី ៥០ នៃទិវាបង្កើតសភាប្រឹក្សាកិច្ចការអន្តរជាតិនៃ ក្រុងនេះ ។ មេដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោម ត្រូវបាន អញ្ជើញឲ្យចូលរួមក្នុងពិធីបុណ្យនេះដែរ ហើយលោក ប្រាក់ សិរីវុឌ្ឍ អនុប្រធានប្រតិបត្តិ ទទួលបន្ទុក ទំនាក់ទំនងអន្តរជាតិ និង លោក ខែលវិន លី ជាប្រធាននាយកដ្ឋាន រៃបសាយនៃសហព័ន្ធបាន ទៅចូលរួមតាមសេចក្តីអញ្ជើញ ។

នៅក្នុងពិធីនេះ គេសង្កេតឃើញមានការ ចូលរួម របស់អ្នកមុខអ្នកការជាតិ និងអន្តរជាតិ ជាច្រើនរូប រួមមានលោក ខបភី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក ចន នេក្រូពន្ទេ អគ្គរដ្ឋទូតសហរដ្ឋ ប្រចាំអង្គការ សហប្រជាជាតិ និងលោក ឡៃរីយិង អ្នកសារ-ព័ត៌មានដ៏ល្បីនៃសហរដ្ឋអាមេរិក ។ល។

លោក ខបភី អាណាន់ អគ្គលេខាធិការ អង្គការសហប្រជាជាតិ បានជម្រាបអំពីស្ថានការណ៍ ពិភពលោក រួមបញ្ចូលទាំងការកាត់ទោសមេខ្មែរក្រហម ក្នុងប្រទេសកម្ពុជា ការកាត់ទោសលោក Slobodan Mil-osevic អតីតប្រធានាធិបតី យ៉ូហ្គូស្លាវី ។ល។ លោក បានសង្កត់ធ្ងន់ថា ការការពារសិទ្ធិមនុស្សជាកត្តាសំខាន់ បំផុតសម្រាប់សន្តិភាព និង យុត្តិធម៌នៃមនុស្សជាតិ ។

ប្រតិភូសហព័ន្ធខ្មែរកម្ពុជាក្រោម បានជួបសន្ទនា ជាមួយលោក ចន នេក្រូពន្ទេ អគ្គរដ្ឋទូតសហរដ្ឋប្រចាំ អង្គការសហប្រជាជាតិ ។ ទីបញ្ចប់ ប្រតិភូសហព័ន្ធខ្មែរ កម្ពុជាក្រោម បានផ្ញើលិខិតមួយច្បាប់ជាផ្លូវការជូនចំពោះ



*លោក ខែលវិន លី លោក ចន នេក្រូពន្ទេ និង លោក ប្រាក់ សិរីវឌ្ឍ*

លោក អគ្គលេខាធិការ អង្គការសហប្រជាជាតិ ស្តីអំពីស្ថានការកម្ពុជាក្រោម ដែលខ្មែរក្រោមកំពុងតែពើបប្រទះការលំបាក ដោយត្រូវរស់នៅក្រោមការត្រួតត្រា នៃរបបអាណានិគមយួនកុម្មុយនិស្តបច្ចុប្បន្ន ព្រមទាំងឯកសារនានាដែលលោកអគ្គលេខាធិការអង្គការ UNPO បានផ្ញើដល់រដ្ឋអំណាចវៀតណាម ស្តីអំពីការទាមទារសិទ្ធិរបស់ខ្មែរក្រោម ៕

*ទ្រីវ ភូនាន់*

# ខ្មែរក្រោមនៅភ្នំពេញ ប្រារព្ធពិធីបុណ្យសិទ្ធិមនុស្សលើកទី ៤ ជាប្រវត្តិសាស្ត្រ

កាលពីព្រឹកថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០០៣ នៅសណ្ឋាគារ មេគង្គ រាជធានីភ្នំពេញ មានប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី ៥៥ ដែលរៀបចំឡើងដោយគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម ដោយមានការចូលរួមពីប្រជាជនខ្មែរកម្ពុជាក្រោម ប្រមាណជាង ៥០០ នាក់ ក្នុងគោលបំណងដើម្បីអំពាវនាវឲ្យបងប្អូនខ្មែរកម្ពុជាក្រោម មានសិទ្ធិដូចប្រជាជនទូទៅនៅលើពិភព–លោកដែរ ។

លោក គឹម វណ្ណឆេង ប្រធានគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម បានថ្លែងនាឱកាសនោះថា ការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ ឆ្នាំ ២០០៣ នេះ គឺជាការប្រារព្ធលើកទី ៤ ហើយរបស់បងប្អូនខ្មែរកម្ពុជាក្រោម ដើម្បីបង្ហាញសាធារណៈជាតិ ឲ្យបានដឹងបានឮ ពីការបាត់បង់សិទ្ធិសេរីភាពរបស់បងប្អូនខ្មែរកម្ពុជាក្រោម នៅកម្ពុជាក្រោមដូចសព្វថ្ងៃនេះ ហើយលោកសូមអំពាវនាវដល់ថ្នាក់ដឹកនាំខ្មែរគ្រប់ជាន់ថ្នាក់ ស្ថានទូតនានាប្រចាំនៅប្រទេសកម្ពុជា អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ មេត្តាជួយធ្វើអន្តរាគមន៍ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

ដើម្បីចូលរួមក្នុងទិវានេះ សហព័ន្ធខ្មែរកម្ពុជាក្រោម បានផ្ញើសុន្ទរកថាមួយច្បាប់មកចូលរួម ដែលអានដោយលោកតាំង សារៈ តំណាងសហព័ន្ធខ្មែរកម្ពុជាក្រោម ថ្លែងអំពីទុក្ខសោករបស់បងប្អូនខ្មែរក្រោម ដែលរស់នៅក្រោមនឹមដែកអាណានិគមយួនសព្វថ្ងៃនេះ និងបានទាមទារឲ្យអាជ្ញាធរយួន ត្រូវបញ្ឈប់ធ្វើអាណានិគមលើទឹកដីកម្ពុជាក្រោម ដែលជាមាតុភូមិរបស់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម មានទំហំ ៦៨.៦០០ គីឡូម៉ែត្រក្រឡា ដែលលាតសន្ធឹងនៅភាគខាងត្បូងបំផុត នៃប្រទេសវៀតណាមបច្ចុប្បន្ន ហើយត្រូវដាក់ដែនដីកម្ពុជាក្រោមនៅក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ ដើម្បីបង្កើតឲ្យមានបរិយាកាសសេរី និងយុត្តិធម៌ ដើម្បីផ្តល់ឱកាសឲ្យប្រជា–ពលរដ្ឋខ្មែរកម្ពុជាក្រោម អាចអនុវត្តនូវសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។

ស្ថិតនៅឱកាសនេះដែរ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ពង្សនារី មុនីពង្ស ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ របស់ព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ និងសម្តេចព្រះរាជអគ្គមហេសី មុនីនាថ បានមានព្រះសវនីយ៍ថា ព្រះករុណាជាអង្គម្ចាស់ជីវិតតម្កល់លើត្បូង និងសម្តេចព្រះរាជអគ្គមហេសី ព្រះអង្គ បានសព្វព្រះរាជហឫទ័យផ្ញើសេចក្តីនឹករឭក និងសួរសុខទុក្ខ ព្រមទាំងប្រទានពរដល់ប្រជាពលរដ្ឋ ខ្មែរកម្ពុជាក្រោម ជាកូនចៅរបស់ព្រះអង្គនៅគ្រប់ទិសទី ហើយនិងព្រះអង្គបានប្រទានព្រះរាជទ្រព្យចំនួន ២.០០០ ដុល្លារដល់គណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោមផងដែរ ។ ដែលវិសេសវិសាលជាងនេះទៅទៀតនោះគឺ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ពង្សនារី មុនីពង្ស អ្នកអង្គម្ចាស់ បានប្រកាសសម្ព័ន្ធភាពរបស់អ្នកអង្គម្ចាស់រវាងខ្មែរកម្ពុជាក្រោមជាលើកទី ២ ក្នុងអំឡុងទិវាបុណ្យសិទ្ធិមនុស្សពីរឆ្នាំបន្តបន្ទាប់នេះ ដោយអ្នកអង្គម្ចាស់ប្រកាសថាជីតារបស់អ្នកអង្គម្ចាស់ជាខ្មែរកម្ពុជាក្រោម មាននាមថា សឺន ឡៀប ហើយអ្នកអង្គម្ចាស់គាំទ្រយ៉ាងពេញទំហឹងនៅរាល់សកម្មភាពរបស់ខ្មែរកម្ពុជាក្រោម ដែលស្របទៅតាមគតិច្បាប់ជាតិ និងអន្តរជាតិ ។

នេះជាសក្ខីកម្ម នៃសេចក្តីស្រេកឃ្លាននូវសិទ្ធិសេរីភាពរបស់ប្រជាជាតិខ្មែរកម្ពុជាក្រោមនៅគ្រប់ទិសទី ។ សូមឲ្យបណ្តាប្រទេសដែលស្រឡាញ់យុត្តិធម៌ មេត្តាជួយគាំទ្រនូវសុឆន្ទៈនេះផង ។ ក៏ដើម្បីមនុស្សជាតិលើលោកនេះមានសុភមង្គល ៕

*លី ឈួន*

# វត្តសំរោងឯក សម្រែកខ្មែរក្រោម

*ដកស្រង់ចេញពីទស្សនាវដ្ដី អង្គរធំ*

*វត្តសំរោងឯក ត្រូវបានកសាងឡើងមុនគេបង្អស់ នាចុងសម័យនគរភ្នំ និងដើមយុគសម័យចេនឡា ក្នុងគ.ស. ៦៤២ ក្នុងរជ្ជកាលព្រះបាទភវវរ្ម័ន (៦៣៥–៦៥៥) គឺនៅពេលដែលព្រះអង្គយាងត្រឡប់ពីធ្វើសឹកសង្គ្រាម យកប្រទេសចាមធ្វើជាចំណុះប្រទេសខ្មែរប្រកបដោយជោគជ័យ ហើយបានត្រាស់បង្គាប់ឲ្យពួកមេទ័ព បោះព្រះពន្លាជ័យនៅលើទួលដើមសំរោងក្បែរត្រពាំងមួយ ។ ពេលផ្ទំសម្រាក នៅលើទួលនោះ ព្រះអង្គបានសុបិនឃើញព្រះពុទ្ធបដិមាមួយអង្គ ផុសឡើងនៅត្រង់គល់ដើមសំរោងមួយ លុះព្រះអង្គភ្ញាក់តើនឡើង ព្រះអង្គត្រាស់បញ្ជា ឲ្យពួកមេទ័ពជីកកកាយត្រង់កន្លែងសុបិន ឃើញព្រះពុទ្ធបដិមាផុសឡើង នោះក៏ប្រទះឃើញពុទ្ធបដិមាសំរឹទ្ធិទ្រង់គង់ព្រះភ្នែន កម្ពស់ ១,២ ម ព្រះអង្គក៏រៀបចំកសាងវត្តមួយនៅលើទួលសំរោងតែម្តងទៅ ។*



*វត្តសំរោងឯក កសាងនៅ ព.ស. ១១៨៦ គ.ស. ៦៤២*

វត្តសំរោងឯក ស្ថិតនៅ ក្នុងភូមិធ្លក ឃុំធ្លក ស្រុកភ្នំដាច់ ខេត្តព្រះត្រពាំង ដែលយួនប្តូរឈ្មោះថាខេត្ត ត្រាវិញ (Tra Vinh) ហើយមានចម្ងាយពីរាជធានីភ្នំពេញប្រមាណ ៤១២ គីឡូម៉ែត្រ បើធ្វើដំណើរតាមផ្លូវជាតិលេខ ២១ តាមច្រកទ្វារជ្រៃធំ ស្រុក កោះធំ ខេត្តកណ្តាល ។

វត្តសំរោងឯក គឺជាវត្តមានវ័យចំណាស់ជាងគេគ្មានពីរ នៅលើទឹកដីកម្ពុជាក្រោម ក៏ដូច ជាទឹកដីកម្ពុជាកណ្តាលយើងនេះដែរ ។ វត្តនេះ កសាងឡើងនៅ ព.ស. ១១៨៦ គ.ស. ៦៤២ ក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី ២ (គ.ស. ៦៣៥–៦៥៥) ហើយបើគិតមកដល់ឆ្នាំ ២០០៣ នេះ គឺមានអាយុកាល ១៣៦១ ឆ្នាំហើយ ពោលគឺវត្តនេះត្រូវបានកសាងឡើងពីចុងយុគសម័យអាណាចក្រភ្នំ និងដើមយុគសម័យចេនឡាមកម្ល៉េះ ។ ក្នុងសម័យនោះប្រទេសកម្ពុជាយើង គឺជាចក្រភពដ៏ខ្លាំងពូកែ មានព្រំប្រទល់ខាងជើងទល់នឹងក្រុងហ្លួងព្រះបាង (ក្រុងវៀងច័ន្ទ) ប្រទេសលាវ ។ ខាងកើតទល់នឹងប្រទេសចម្ប៉ា និងដែនសមុទ្រចិន ខាងត្បូងទល់នឹងមហាសមុទ្រចិន ខាងត្បូងទល់នឹងមហាសមុទ្រ និងខាងលិចទល់នឹងប្រទេសម៉ាឡេយូ ។

ព្រះបាទភវវរ្ម័ន ទ្រង់បានត្រាស់បង្គាប់ឲ្យពួកនាម៉ឺនកសាងវត្តនេះឡើង គឺដើម្បីឧទ្ទិសថ្វាយពុទ្ធសាសនា បន្ទាប់ពីព្រះអង្គដឹកនាំធ្វើសឹកសង្គ្រាមវាយយកប្រទេស ចម្ប៉ាមកធ្វើជាចំណុះរបស់ប្រទេសខ្មែរយើង ។

បើតាមការរៀបរាប់របស់ព្រះសង្ឃ និងពួកពុទ្ធបរិស័ទចំណុះជើងវត្តសំរោងឯកនោះ បានឲ្យដឹងថាបើតាមការដំណាលតៗគ្នា តាំងពីជំនាន់ដើមរហូតដល់ជំនាន់សព្វថ្ងៃនេះ បានបញ្ជាក់ថា នៅពេលដែលព្រះបាទភវវរ្ម័នដឹកនាំកងទ័ពវាយយកប្រទេសចម្ប៉ា ធ្វើជាចំណុះប្រកបដោយជោគជ័យមក ស្តេចចម្ប៉ាក៏សុខចិត្តនាំយកសួយសារអាករមកថ្វាយស្តេចខ្មែរជារៀងរាល់ឆ្នាំ ហើយព្រះអង្គបានដាក់ព្រះរាជតំណាងរបស់ព្រះអង្គ និង កងទ័ពខ្មែរមួយចំនួននៅក្នុងប្រទេសចម្ប៉ានេះ ដើម្បីមើលការខុសត្រូវជំនួសព្រះអង្គទីនោះរួចរាល់ហើយ ព្រះអង្គក៏នាំទ័ពសេះ ទ័ពដំរី ទ័ពថ្មើរជើងវិលត្រលប់មកព្រះនគរវិញ ។

កាលសម័យនោះ ទឹកដីខ្មែរកម្ពុជាក្រោម សម្បូរទៅដោយព្រៃឈើធំៗ ឯជនជាតិខ្មែរយើងមានចំនួនតិចតួច ហើយច្រើនរស់នៅដោយប្រមូលផ្តុំបង្កើតជាភូមិតូច ៗ នៅក្នុងព្រៃស្រោងនោះទៀតផង ។

ពេលព្រះអង្គនាំកងទ័ពមកដល់ព្រៃមួយ ដែលសំបូរទៅដោយដើមធ្លក និងជាតំបន់ដាច់ភ្នំ (គ្មានភ្នំ) គឺ

មានតែត្រពាំង បឹងបួរ ព្រះអង្គក៏ត្រាស់បង្គាប់ឲ្យនាម៉ឺន របស់ព្រះអង្គបោះព្រះពន្លាជ័យនៅទីនោះ ដើម្បីឲ្យកង ទ័ពរបស់ព្រះអង្គប្រមាណ ២ សែននាក់សម្រាកយក កម្លាំងមួយរយៈសិន ។

ពួកនាម៉ឺន បានរៀបចំព្រះពន្លាជ័យមួយកន្លែង នៅក្រោមដើមសំរោងដ៏ធំមួយដើម មានម្លប់ត្រជាក់ ត្រឈឹងត្រឈៃ ស្ថិតនៅជាប់មាត់ត្រពាំង ។ ដោយសារ មានការហត់នឿយព្រះកាយ ក្នុងការធ្វើសឹកសង្គ្រាម និងការយាងដំណើរដ៏សែនឆ្ងាយ ព្រះអង្គក៏ប្រះព្រះ–កាយលង់លក់ នៅក្នុងព្រះពន្លាជ័យនោះយ៉ាងស្កប់–ស្កល់ ហើយព្រះអង្គទ្រង់សុបិន្តឃើញព្រះពុទ្ធបដិមា មួយអង្គ ធ្វើអំពីសំរឹទ្ធិ ទ្រង់គង់ព្រះភ្នែនកម្ពស់ ១,២ ម បានផុសចេញពីដីត្រង់គល់ដើមសំរោង ជាប់នឹងសំ–យាបព្រះពន្លាជ័យ របស់ព្រះអង្គស្រស់ៗ នឹងព្រះនេត្រ ។ ភ្លាមនោះព្រះអង្គក៏តើនឡើង ហើយទតមើលម្តុំគល់ដើម សំរោង ក៏ឃើញកន្លែងមួយរាងក្រហូង ហើយប្រេះបន្តិចៗ ផង ហាក់ដូចជាមានវត្ថុអ្វីមួយប្រុងផុសចេញពីក្រោមដី ផុសចេញពីក្រោមដីមក ។ ព្រះអង្គ ឃើញបាតុភូតចម្លែក ដូច្នោះ ទ្រង់ក៏ត្រាស់បង្គាប់ឲ្យពួកនាម៉ឺននិងមេទ័ពកំពូលៗ របស់ព្រះអង្គ មកជួបជុំ ហើយមានរៀបរាប់ពីដំណើររឿង ដែលព្រះអង្គទ្រង់សុបិននោះឲ្យពួកនាម៉ឺន និង មេទ័ព កំពូលៗ ឲ្យបានដឹងគ្រប់ ។ គ្នារួចហើយ ទ្រង់ត្រាស់បញ្ជា ឲ្យមេទ័ពកំពូលម្នាក់ទៅពិនិត្យ និងកាយដីត្រង់កន្លែងមាន បាតុភូតចម្លែកនោះ តើមានហេតុភេទអ្វីទៅ ?

នៅពេលដែលមេទ័ពកំពូល យកដៃទៅកាយដី ដែលផុសៗនោះតែបន្តិច ក៏ស្រាប់តែប៉ះនឹងព្រះកេស របស់ព្រះពុទ្ធបដិមាមួយអង្គ ធ្វើពីសំរឹទ្ធិខ្មៅរលោងស្រិល ។ ទតឃើញដូច្នេះ ព្រះអង្គក៏ត្រាស់បញ្ជាឲ្យពលសេនានាំគ្នា ជីកកកាយដីនៅម្តុំជុំវិញព្រះពុទ្ធបដិមានោះថ្នមៗ កុំឲ្យមាន ការប៉ះទង្គិចត្រូវព្រះបដិមានោះឲ្យសោះ ។ ក្រោយពីជីកលុងជុំវិញអស់ហើយនោះ ក៏ឃើញព្រះពុទ្ធ បដិមានោះមានកម្ពស់ ១,២ ម ដូចទ្រង់សុបិនឃើញយ៉ាង ដូច្នេះមែន ។ ព្រះអង្គបានត្រាស់បញ្ជាឲ្យពលសេនាទាំង អស់ នាំគ្នាសែងព្រះពុទ្ធបដិមានោះឡើងមកលើ ។ តែ ទោះបីពលសេនាមានច្រើន រាប់សែននាក់ក៏ដោយ ក៏គ្មាន លទ្ធភាពក្នុងការលើកព្រះពុទ្ធបដិមានោះ ចេញពីរណ្តៅ ឡើងមកលើបានដែរ ។

ព្រះអង្គ ទតឃើញហេតុការណ៍ចម្លែកអស្ចារ្យ យ៉ាងដូច្នេះ ទ្រង់ក៏ឲ្យលោកតាហោរា ធ្វើការគន់គូរវាយ លេខអត្តៈ មើលតើមកពីហេតុអ្វីបានជាពលសេនារាប់ ម៉ឺននាក់មិនអាចលើកយកព្រះពុទ្ធបដិមាសំរឹទ្ធិនោះ ចេញ ពីក្នុងរណ្តៅបាន ?

លោកតាហោរ ក៏ប្រញាប់ប្រញាល់ទាញក្តារ វាយលេខអត្តៈ ហើយទូលថ្វាយព្រះអង្គថា *«ក្រាបទូល ទួលនេះ គឺជាទួលដែលមានបារមីខ្លាំងពូកែ ហើយត្រូវ កសាងវត្តអារាមមួយនៅលើទួលនេះ និងតម្កល់ព្រះ–បដិមាសំរឹទ្ធិនៅក្នុងវត្តនេះ ទុកជាទីគោរពបូជារបស់ប្រជា រាស្ត្រខ្មែរជាពុទ្ធសាសនាតរៀងទៅ ។ ចំពោះការលើក ព្រះពុទ្ធបដិមាចេញពីក្នុងរណ្តៅមកគឺងាយទេ ព្រោះព្រះ–អង្គ ធ្វើអធិដ្ឋានរំឭកនឹកដល់គុណព្រះពុទ្ធ ជាព្រះបរមគ្រូ រួចហើយយកអំបោះតៃ ៧ សរសៃ ទៅចងទាញស្ទួចយក ព្រះពុទ្ធបដិមានោះទៅ គឺប្រាកដជាបានសម្រេចដូច ព្រះទ័យប៉ងប្រាថ្នារបស់ព្រះអង្គជាមិនខាន»* ។

ព្រះបាទភវវរ្ម័ន ក៏បានធ្វើតាមការទស្សន៍ទាយ របស់លោកតាហោរា ដោយលើកព្រះហស្តទាំងទ្វេអញ្–លីលើព្រះសិរសា សន្យានៅចំពោះវត្ថុសក្តិសិទ្ធិដែលនៅ ថែរក្សាទួលព្រៃសំរោងនោះថា ព្រះអង្គនឹងត្រាស់បង្គាប់ ឲ្យកសាងវត្តមួយនៅលើទួលនេះ តាមការគន់គូររបស់ លោកតាហោរ រួចហើយទ្រង់ត្រាស់បង្គាប់ឲ្យមេទ័ពកំពូល យកអំបោះ ៧ សរសៃ ចងស្រាក់ជុំវិញព្រះពុទ្ធបដិមា នោះ ហើយត្រាស់បញ្ជាឲ្យមេទ័ព តែ ៤ នាក់ ឈរជុំវិញ ទិសទាំង ៤ នៅមាត់រណ្តៅឲ្យទាញយោងព្រះពុទ្ធបដិមា នោះ ឡើងមកលើយ៉ាងងាយបំផុត ហាក់ដូចជាស្រាលដូច សំឡីយ៉ាងដូច្នេះ ដែរ ។

ក្រោយពីលើកយកព្រះពុទ្ធបដិមានោះ ចេញពី រណ្តៅរួចមកហើយ ព្រះអង្គក៏ត្រាស់បញ្ជាឲ្យកងទ័ពឲ្យទៅ កេណ្ឌប្រមូលពួកអ្នកស្រុក ដែលរស់នៅតំបន់នោះ មក រួមកម្លាំងគ្នាជាមួយកងទ័ពរបស់ព្រះអង្គដើម្បី ចាប់ផ្តើម កសាងវត្តអារាមមួយ នៅលើទួលសំរោងនោះ ។

ព្រះបាទភវវរ្ម័ន ទ្រង់បានគង់នៅលើទួលសំ–

រោងនោះ រហូតដល់កសាងវត្តនៅលើទួលសំរោងនោះរួចរាល់ជាស្ថាពរហើយព្រះអង្គ បានរៀបចំតម្កល់ព្រះ–បដិមាសំរឹទ្ធិ ទ្រង់ព្រះភ្នែនកម្ពស់ ១,២ ម នោះ ដាក់ក្នុងព្រះវិហារ និងបានយកព្រះវិស្ណុមួយអង្គទៀតធ្វើពីថ្លើមថ្មដាក់អមនៅសងខាងព្រះពុទ្ធបដិមាសំរឹទ្ធិនោះទៀតផង ។ ព្រះអង្គត្រាស់បង្គាប់ឲ្យពួកព្រាហ្មបុរោហិតម្នាក់ ធ្វើជាអធិការវត្ត ហើយទ្រង់ប្រសិទ្ធិនាមវត្តនោះថា «*វត្តសំរោងឯក*» ទៀតផង ។

មូលហេតុដែលធ្វើឲ្យព្រះបាទភវវរ្ម័ន ទ្រង់រៀបចំដាក់រូបចម្លាក់ព្រះនារាយណ៍ និងព្រះវិស្ណុនៅអមសងខាងព្រះពុទ្ធបដិមាសំរឹទ្ធិនោះ ព្រោះព្រះអង្គយល់ថាប្រជារាស្ត្រខ្មែរគឺជាអ្នកកាន់ព្រះពុទ្ធសាសនាផង និង ព្រហ្មញ្ញសាស–នាផង ដូច្នេះដើម្បីកុំឲ្យប្រជារាស្ត្ររបស់ព្រះអង្គនៅទីនោះមានជម្លោះបាក់បែកគ្នា ដោយសារបញ្ហាជំនឿសាសនា ព្រះអង្គបានសម្រេចព្រះទ័យរៀបចំតាមរបៀបនេះ តែម្តងទៅ ។

ដោយសារវត្តសំរោងឯកនេះ ស្ថិតនៅឆ្ងាយពីភូមិអ្នកស្រុក ព្រះអង្គក៏បានកេណ្ឌប្រជារាស្ត្រមួយចំនួនឲ្យមកសង់ផ្ទះសម្បែងក្បែរវត្ត បង្កើតបានជាភូមិមួយថា ភូមិធ្លក និងបង្កើតបានជាឃុំមួយដាក់ឈ្មោះថា ឃុំធ្លក ដែរ ព្រោះនៅទីនោះសម្បូរទៅដោយដើមធ្លកធំៗ ជាច្រើន ។ ជាមួយគ្នានេះដែរ ព្រះអង្គបានដាក់ឈ្មោះ ស្រុកនោះថា ស្រុកភ្នំដាច់ ព្រោះតំបន់នោះគ្មានភ្នំមួយឡើយ និងដាក់ឈ្មោះខេត្តនោះថាខេត្តព្រះត្រពាំងទៀតផង ។

ព្រះអង្គបានរៀបចំព្រះពិធីបុណ្យបញ្ចុះសីមា នៅវត្តសំរោងឯករួចរាល់ហើយ ទើបបន្តដំណើរយាងចូលវិលត្រឡប់ដល់ព្រះបរមរាជវាំងវិញ ។

ចាប់ពីពេលនោះមក វត្តសំរោងឯកក៏មានកូនចៅអ្នកភូមិមួយចំនួន នាំគ្នាទៅសាងផ្នួសបួសរៀនគម្ពីរព្រះពុទ្ធសាសនា ជាបន្តបន្ទាប់ ពីជំនាន់មួយទៅជំនាន់មួយទៀតជាហូរហែរ ឯប្រជារាស្ត្រដែលរស់នៅក្នុងតំបន់នោះ ក៏បាននាំគ្នាកាប់ឆ្ការព្រៃរុករានដីធ្វើស្រែចំការ កសាងជីវភាពយ៉ាងសុខដុមរមនា ត្រដាក់ត្រដុំ តកូនចៅដរាបរៀងមក ។

លុះមកដល់រជ្ជកាលព្រះបាទអង្គអេង (១៧៧០–១៧៩៦) មានស្តេចយួនមួយអង្គឈ្មោះ យ៉ា ឡុង ត្រូវស្តេចយួនមួយអង្គនៅភាគខាងជើង លើកកងទ័ពមកវាយដណ្តើមយករាជសម្បត្តិ ធ្វើឲ្យស្តេចយួនអង្គនេះ រត់ខ្ចាត់ខ្ចាយ ហើយភៀសខ្លួនចូលមកក្នុងប្រទេសខ្មែរ ហើយបានសុំរាជានុញ្ញាតពីព្រះបាទអង្គអេង ស្នាក់នៅក្នុងខេត្តព្រះត្រពាំង ។ ព្រះបាទអង្គអេង ក៏បានយល់ព្រមអនុញ្ញាតឲ្យព្រះចៅ យ៉ា ឡុង និងបរិពារទាំងអស់រស់នៅក្នុងខេត្តព្រះត្រពាំងនោះជាបណ្តោះអាសន្នសិន ។

ក្រោយមក ដោយសារមានជំនួយពីស្តេចខ្មែរផងនោះ ព្រះចៅ យ៉ា ឡុង ក៏បានធ្វើការវាយបកលើកងទ័ពស្តេចយួន ដែលមកពីភាគខាងជើងនោះ ដណ្តើមបានអំណាច និងរាជសម្បត្តិវិញ ។

ប៉ុន្តែស្តេចយួនព្រះនាមព្រះចៅ យ៉ា ឡុង មិនបាននាំយកប្រជារាស្ត្រយួន ដែលមកសុំជ្រកកោននៅក្នុងខេត្តព្រះត្រពាំងនោះ ត្រឡប់ទៅរស់នៅប្រទេសយួនវិញទេ គឺថែមទាំងកាន់តែបញ្ជូនជនជាតិយួនខាងត្បូង មករស់នៅក្នុងខេត្តព្រះត្រពាំងកាន់តែច្រើនឡើងៗ ហើយថែមទាំងទាមទារមិនឲ្យពួករាជការខ្មែរ យកពន្ធដារលើជនជាតិយួននោះទៀតផង ។

ពេលជនជាតិយួន ចូលមករស់នៅកាន់តែច្រើន ពួកវាក៏ចាប់ផ្តើមធ្វើទុក្ខបុកម្នេញជនជាតិខ្មែរ ដែលជាម្ចាស់ទឹកម្ចាស់ដី យ៉ាងព្រហើនកោងកាចបំផុត តាំងពីរជ្ជកាលព្រះបាទអង្គអេង រហូតដល់រជ្ជកាលព្រះបាទអង្គឌួង ។ បន្តិចក្រោយមក ប្រទេសខ្មែរយើងក៏ដូចជាតំបន់ឥណ្ឌូចិនទាំងមូល ត្រូវធ្លាក់នៅក្រោមអាណានិគមនិយមបារាំង ។

នៅថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៤៩ ពួកអាណានិ–គមនិយមបារាំង ក៏បានសម្រេចកាត់ទឹកដីខ្មែរភាគខាងត្បូង គឺទឹកដីកម្ពុជាក្រោម ទៅឲ្យយួនគួរឲ្យឈឺចាប់រកទីបំផុតគ្មាន ។

បងប្អូនប្រជារាស្ត្រខ្មែរនៅកម្ពុជាក្រោម ក៏បាននាំគ្នាក្រោកឡើង ធ្វើការតស៊ូការពារទឹកដីរបស់ខ្លួនយ៉ាងអង់អាចក្លាហាន ប៉ុន្តែអាជ្ញាធរយួនធ្វើការបង្ក្រាបយ៉ាងសាហាវព្រៃផ្សៃ និងរិះរកគ្រប់មធ្យោបាយដើម្បីបំផ្លិចបំផ្លាញអត្តសញ្ញាណជាតិខ្មែរ ឲ្យរលាយសាបសូន្យអស់ពីទឹកដីកម្ពុជាក្រោម ។ សូម្បីតែព្រះបដិមាសំរឹទ្ធិ រូបចម្លាក់

ព្រះនារាយណ៍ និងព្រះវិស្ណុ ដែលព្រះបាទភវវរ្ម័ន បានយកទៅតម្កល់ទុកក្នុងព្រះវិហារវត្តសំពោងឯកនោះ ក៏អាជ្ញាធរយួនប្រើល្បិចកលយកបាត់អស់ដែរ ។

ដោយសារវត្តសំពោងឯក គឺជាវត្តមួយ ដែលមានវ័យចំណាស់ជាងគេបំផុត និងបានកសាងឡើងនៅលើទឹកដីកម្ពុជាក្រោម នៅក្នុងរជ្ជកាលព្រះបាទភវវរ្ម័ន តាំងពី ១៣៦១ ឆ្នាំមុននោះ ទើបបានជាបងប្អូនខ្មែរកម្ពុជាក្រោមយើង មានជំនឿលើព្រះពុទ្ធសាសនាយ៉ាងរឹងមាំបំផុត រហូតដល់សព្វថ្ងៃនេះ ។

បើតាមការអះអាង របស់បងប្អូនខ្មែរកម្ពុជា-ក្រោមយើង ជាទូទៅបានឲ្យដឹងថា គិតចាប់ពីក្រោយពេល ដែលពួកអាណានិគមនិយមបារាំង ប្រគល់ទឹកដីកម្ពុជាក្រោមទៅឲ្យយួនពីឆ្នាំ ១៩៤៩ មក ពួកយួនបានចាប់ផ្សឹកព្រះសង្ឃខ្មែរចំនួន ៨៤៦ អង្គ ហើយមានមួយចំនួនទៀតត្រូវអាជ្ញាធរយួន ធ្វើទុក្ខបុកម្នេញដាក់គុកច្រវាក់យ៉ាងសាហាវព្រៃផ្សៃ ។

បងប្អូនជនជាតិខ្មែរកម្ពុជាក្រោម ជាពុទ្ធបរិស័ទចំណុះជើងវត្តសំពោងឯក ក៏ដូចជាវត្តផ្សេង ៗ ទៀត នៅលើទឹកដីកម្ពុជាក្រោមដែរ នៅតែប្តេជ្ញាចិត្តមិនចេះរឹងស្ងួតក្នុងការតស៊ូការពារអត្តសញ្ញាណខ្មែរតទៅទៀត យ៉ាងអង់អាចក្លាហានបំផុត លុះត្រាជីវិតចុងក្រោយ ដាច់ខាតមិនឲ្យយួនលុបបំបាត់បានដោយងាយនោះឡើយ ៕




ខ្មែរដាក់ឈ្មោះខ្ញុំ
ពិរោះសែនសម ចំព្រះត្រពាំង ទឹកថ្លាត្រជាក់
ដីកមានកម្លាំង ទោះជាខែប្រាំង មិនរីងហែងស្ងួត។
ត្រពាំងដីកេរ
ដីរបស់ខ្មែរ ស្រែមានជីជាតិ ដីនោះហៅល្អ
បង្ករបង្កើត ផ្លូវផង់ស្រស់ឆើត កំណើតខេមរា ។
ត្រពាំងហៅឆ្មើម
ស្រះនៅខាងដើម សម្បើមអស្ចារ្យ ឈូករីករហង់
រំចង់បុប្ផា មានហ្វូងមច្ឆា ឆ្លេឆ្លាសប្បាយ ។
ត្រពាំងថ្លាឆើត
ទឹកដីត្រើយកើត កំណើតដើមថ្ងៃ រះព្រឿងឡើងលើ
បំភ្លឺលោកិយ ភពផែនដែនដី ព្រៃព្រឹក្សបព្វតា ។
ក្រោយមានប្រវត្តិ
កម្មមកពង្រត់ ចត់ល្វឹងហិរខារ ត្រពាំងបាត់ឈ្មោះ
គ្រោះកាចខ្លោចផ្សា ពួកយួនឫស្យា ប្រហារផ្លាស់ប្តូរ ។
ពីព្រះត្រពាំង
ទៅជាត្រាបាង ខាងដើមទីមក៏ ត្រពាំងសោភា
ផ្សាឈើស្រែកថ្ងូរ ភ្លេចខ្លួនយួនចោរ ឆរបោក យកដី ។
ល្បិចល្បោចដូចខ្លែង
ដឹកនាំរាំលេង បង្វែងខ្មែរប្រុសស្រី កលយួនខិលខូច
លួចធក់ប្លន់ដី ដោយល្បែងស្រាស្រី តែបន្លំលាក់ ។
ប្រើប្រាស់ផ្លាស់ប្រែ
ល្បួចយួនលួចគេ កែកុនយួនដាក់ ត្រាបាងឈ្មោះថ្មី
ភ័យមិនទាន់ស្រាក ត្រាយ៉ាងយួនដាក់ លាក់បំភ័ន្តខ្មែរ ។
ហៅត្រាយ៉ាងយួរ
ប្រើស្មៀតឆ្លៀតដូរ ប្តូរផ្តិនភ្នែកគេ ហៅថាត្រាវិញ
ពេញមាត់អ្នកស្រែ បានយួនខុសខ្មែរ ប្រែជាយិនបិន ។
យួនជើងយួនត្បូង
វ៉ាក់ស៊ីខាញ់ដូង ឡូងឡូវយ៉ាងមិន ត្រឹងត្រាងម៉ាងការ
ធីរតីយឿងមិន ប្រែជាភូយិន មិន ធីរលំ ។
ខ្ញុំព្រះត្រពាំង
ទ្រូងចុកណែនខ្លាំង ខ្ទាំងចាប់បង្ខំ បើសិនវល្លិ៍ឈើ
ស្មើរដោចជាដុំ កាច់មួលឈ្មោះខ្ញុំ រលំដួលតាមយួន ។
យួនថ្មីយួនចាស់
សត្រូវពូជសាសន៍ ផ្លាស់មិនរង្កៀសខ្លួន ច្រើនលើកច្រើនដង
ប៉ងបំបាត់សូន្យ អស់ខ្មែរនៅយួន រុកគួនគ្មានឈប់ ៕

(នៅមានត) ដោយ **ថាច់ សុមេធ**

*ព្រឹត្តិបត្រ កម្ពុជាក្រោម ក្នុងគោលបំណងឆ្លុះបញ្ចាំងនូវសកម្មភាព របស់សហព័ន្ធខ្មែរកម្ពុជាក្រោម និងចលនាតស៊ូដោយសន្តិវិធី ដើម្បីទាមទារសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ជូនប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅលើមាតុភូមិដ៏សែនស្រណោះ របស់យើង សូមព្រះរាជានុញ្ញាតចុះផ្សាយឡើងវិញនូវ ព្រះបន្ទូលថ្លែងការណ៍ នៃសម្តេចព្រះបាទ នរោត្តម សីហនុ ថ្លែងទៅកាន់អង្គការសហប្រជាជាតិ កាលពីថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៦១ ដែលឆ្លុះបញ្ចាំងឲ្យឃើញនូវព្រះរាជហឫទ័យរបស់ព្រះអង្គ ចំពោះជនរួមឈាមខ្មែរកម្ពុជាក្រោម ។*

# រឿងដ៏ខ្លោចផ្សានៃជនជាតិខ្មែរក្រោម

## ដែលសម្តេច ព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋកម្ពុជា ទ្រង់បានរំឭកនៅចំពោះមុខ អង្គការសហប្រជាជាតិ កាលពីថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៦១



### ១-មតិរបស់ជនជាតិខ្មែរ

"ដោយហេតុថាបញ្ហានេះប៉ះពាល់ផ្ទាល់ ដល់សាច់នឹងឈាមយើងយ៉ាងផ្ទាល់តែម្តង", ដោគវាសនាដ៏អភ័ព្វដែលបងប្អូនរួមជាតិខ្មែរយើងបានទទួលនូវ ឯនាយព្រំ-ប្រទល់ដែនផ្នែកខាងកើត បញ្ហាទាំងនេះធ្វើឲ្យយើងក្រៀមក្រំយ៉ាងក្រៃលែង ។

ដោយត្រូវគេបង្ខំ ទុកដូចជាជនបរទេសនៅលើទឹកដីដែលជាកេរ្តិ៍មរតករបស់ខ្លួន នឹងដោយត្រូវរដ្ឋាភិបាលវៀតណាមខាងត្បូង ចាត់ទុកជាជនជាតិយៀកណាមនោះ បងប្អូនរួមជាតិខ្មែរទាំងនេះ បានត្រូវទទួលនូវទារុណកម្មគ្រប់យ៉ាង បើកាលណាខ្លួនចង់រក្សាទុកនូវបុគ្គលិកលក្ខ-ណៈខ្លួន និងបើខ្លួនចង់នៅមានស្វាមីភ័ក្តិចំពោះភាសារបស់ខ្លួន ចំពោះទំនៀមទម្លាប់របស់ខ្លួនចំពោះទម្រង់ការនៃព្រះពុទ្ធសាសនា ដែលខ្លួនត្រូវគោរពប្រតិបត្តិ ។ ជនរួមជាតិខ្មែរទាំងនេះគ្មានការអនុគ្រោះពី "ពួកឧទ្ទាមប្រឆាំងនឹងរដ្ឋាភិបាលព្រៃនគរ" ដែលទទួលការគាំទ្ររដ្ឋការហាណូយនោះដែរ ។

ដោយនាំគ្នាគេចឲ្យផុតពី ការប្រល័យជីវិតនេះ បងប្អូនរួមជាតិយើងជាច្រើនរយ បានរិះរកផ្លូវគេចរត់ឆ្លងព្រំដែនមកជ្រកកោននៅលើទឹកដីជាតិខ្មែរ ។ ក៏ប៉ុន្តែបងប្អូនរួមជាតិទាំងនេះពុំអាចភៀសខ្លួនបានទាំងអស់គ្នាទេ ។ ដោយមានការតាមដេញប្រកិត, ការចាប់ចងជនរួមជាតិយើងទាំងនេះ បានខូចបង់នូវជីវិតជាញឹកញាប់ក្នុងការរត់ភៀសខ្លួនពុំបានសម្រេចផលនេះ ។

សម្តេចព្រះប្រមុខរដ្ឋទ្រង់ បានយកព្រះទ័យទុកដាក់ ចំពោះសំណូមពរទាំងនេះ ដោយទ្រង់បានដាក់ជូនមហាសន្និបាតនៃអង្គការសហប្រជាជាតិលើកទី ១៦ នេះ នូវបញ្ហានៃអានីតិជនខ្មែរនៅវៀតណាមខាងត្បូង ហើយទ្រង់បានសុំនៅឱកាសនោះ ឲ្យគេទទួលធានាអះអាងចំពោះសិទ្ធិនៃអានីតិជនទាំងអស់ ដែលនៅក្នុង

តំបន់ផ្សេង ៗ ក្នុងសាកលលោកផង ។

អន្តរាគមន៍នេះ មាននៅក្នុងសេចក្តីថ្លែងការណ៍របស់សម្តេចសហជីវិន ដែលទ្រង់បានថ្លែង កាលពីថ្ងៃទី ២២ កញ្ញា ឆ្នាំ ១៩៦១ នៅលើវេទិកានៃមហាសន្និបាត ។ សេចក្តីស្រង់ទាំងបីផ្នែកនៃសេចក្តីថ្លែងការណ៍នេះ ដែលទាក់ទងនឹង "ខ្មែរក្រោម" យើងសូមដកស្រង់យកមកចុះផ្សាយដូចតទៅ ។

ការផ្ទេរដែនដីនៃរដ្ឋកូសាំងស៊ីនពីដើម ឲ្យដល់រដ្ឋាភិបាលវៀតណាម ហើយដែលមានរំឭកការដកស្រង់ពីវគ្គខាងដើមការចុះផ្សាយនេះសម្តេចសហជីវិន បាននាំមកដំណាលក្នុងរឿងដោះស្រាយដោយសន្តិវិធីដល់ បញ្ហាអាល់ហ្សេរី ការផ្ទេរនេះកំណត់អំពីឫសកំណើតនៃបញ្ហាដ៏ក្តុកក្តួលរបស់ពួក "ខ្មែរក្រោម" ដែលជាកម្មវត្ថុរបស់សេចក្តីថ្លែងការណ៍នៃសម្តេចព្រះប្រមុខរដ្ឋ ។

### ២-ព្រះបន្ទូលថ្លែងការណ៍នៃសម្តេចព្រះប្រមុខរដ្ឋកម្ពុជា

ប្រទេសកូសាំងស៊ីន ដែលជាវៀតណាមខាងត្បូងសព្វថ្ងៃនោះ ជាដីរបស់កម្ពុជាដែលប្រទេសអណ្ណាម បានកាន់កាប់មួយភាគ នៅពេលដែលជនជាតិបារាំងបានមកដល់កាលពីពាក់កណ្តាលសតវត្សទី ១៩ ។ កាលនោះប្រទេសបារាំងបានទុក អាណាខេត្រទាំងនេះឲ្យស្ថិតនៅក្រោមអំណាចរបស់ខ្លួនតែម្តង ព្រមទាំងខេត្រទាំង-ឡាយ ដែលនៅកើតវិវាទរវាងប្រទេសកម្ពុជា នឹងប្រទេសអណ្ណាម ហើយបារាំងក៏យកដែនដីនឹងខេត្រទាំងនោះ ធ្វើជាអាណានិគមមួយ រួចធ្វើជាខេត្រមួយរបស់បារាំងដោយជ្រើសតាំង អ្នកតំណាងឲ្យទៅនៅប្រជុំក្នុងសភា របស់បារាំង ។

កាលពីឆ្នាំ ១៩៤៦-៤៧ ដោយហេតុប្រទេសបារាំង ត្រូវតស៊ូបង្ក្រាបការបះបោររបស់វៀតណាម ដែលមានកម្លាំងជាពិសេសនៅប៉ែកខាងជើងនោះ ប្រទេសបារាំងក៏បង្កើត ឲ្យមានរដ្ឋាភិបាលបណ្តោះអាសន្នមួយនៅវៀតណាមខាងត្បូង ។ រួចកាលពីឆ្នាំ ១៩៤៨-៤៩ ប្រទេសបារាំងបានហៅបាវដាយ ជាអតីតព្រះមហាក្សត្រដែលត្រូវដាក់រាជ្យកាលពីឆ្នាំ ១៩៤៥ នោះមកវិញបាន ប្រកាសតាំងបាវដាយ ឲ្យធ្វើជាប្រមុខរដ្ឋ ហើយផ្ទេរកូសាំងស៊ីន ជាដីរបស់បារាំងមកឲ្យបាវដាយ ដោយមានសេចក្តីយល់ព្រមរបស់រដ្ឋសភាបារាំង ។ ព្រះមហាក្សត្រនៃប្រទេសកម្ពុជា ព្រះអង្គទ្រង់ក៏បានតវ៉ាជាផ្លូវការជំទាស់នឹងការផ្ទេរដែនដីនេះ ដែលប្រទេសរបស់យើងបានរក្សាសិទ្ធិរបស់ខ្លួនត្រឹមត្រូវ តាមច្បាប់នៅលើដែនដីនោះតែការតវ៉ានេះជាការឥតអំពើ ។

--------------------

ម្យ៉ាងទៀតប្រទេសបារាំង បានទទួចពោលពីករណីកិច្ចរបស់ខ្លួន ចំពោះជនជាតិបារាំងរាប់លាននាក់ដែលរស់នៅប្រទេសអាល់ហ្សេរី ។ សេចក្តីប្រោសប្រណីនេះត្រឹមត្រូវ នឹងអាចឲ្យគេយោគយល់បានណាស់ប៉ុន្តែបណ្តាលឲ្យខ្ញុំត្រូវរំឭកដល់វាសនា នៅសហគមន៍ខ្មែរចំនួន ៦០០,០០០ នាក់ ដែលរស់នៅដោយគ្មានការធានាអះអាងបន្តិចបន្តួចណា ពីរដ្ឋាភិបាលវៀតណាមខាងត្បូងទេ ។ ម្យ៉ាងទៀតជនរួមជាតិ ៦០០,០០០ នាក់នេះ ពិតជាអ្នកកាន់កាប់ទឹកដីនោះមុនគេផង នេះគឺមិនមែនជាករណីខុសគ្នា នឹងករណីនៃជនជាតិបារាំងនៅប្រទេសអាល់ហ្សេរីទេ ។ ក៏ប៉ុន្តែ ខ្ញុំមានជំនឿថាមេដឹកនាំអាល់ហ្សេរីទាំងឡាយ មុខជាបើកឲ្យមានការធានាអះអាងជនជាតិបារាំងទាំងនោះ ដែលយើងមិនហ៊ានសង្ឃឹមថា គេព្រមធានារ៉ាប់រងចំពោះជនរួមជាតិទាំងឡាយរបស់យើង ដែលស្ថិតនៅក្រោមនីតិកម្មរបស់វៀតណាមខាងត្បូងទេ ។

នៅពេលនេះ ខ្ញុំសូមអភ័យទោសដល់ប្រតិភូដ៏ជាទីគោរពទាំងឡាយ ចំពោះសុន្ទរកថាដ៏វែងនេះ ហើយខ្ញុំសូមចំពោះអង្គការរបស់យើង សុំគិតដល់បញ្ហាមនុស្សធម៌ ដែលតាមយោបល់របស់ខ្ញុំ ត្រូវធ្វើឲ្យអង្គការនេះយកចិត្តទុកដាក់គិតឲ្យបានដិតដល់ ។ បញ្ហានេះគឺជាបញ្ហាអានីតិជន ហើយជាពិសេសបញ្ហាសហគមន៍ ដែលរស់នៅក្នុងប្រទេសដទៃៗ ។

បញ្ហានេះប៉ះពាល់ផ្ទាល់ដល់យើង, ព្រោះថាជនរួមជាតិរបស់យើងចំនួន ៦០០,០០០ នាក់ បានរស់នៅក្នុងយៀកណាមខាងត្បូង ប្រកបដោយនូវលក្ខណៈដ៏

លំបាកក្រៃលែង ហើយគ្មានអ្វីជាទីពឹងទាល់តែសោះ ដើម្បីទល់នឹងវិធានការ ជាពិសេសដែលគេធ្វើរំលោភមកលើនោះទេ ។ សហគមន៍ខ្មែរនៅយៀកណាមខាងត្បូង គឺជាម្ចាស់ទឹកដីជាដំបូងមក ដែលការលុកលុយរបស់ជនជាតិយៀកណាម បានមកគ្របសង្កត់បាត់អស់ទៅនោះ, ប៉ុន្តែនៅតែរក្សាឯកភាពដ៏ពេញលេញខាងសាសនា, ខាងភាសា, ខាងទំនៀមទម្លាប់ នឹងប្រពៃណី ។ ដោយមានសេចក្តីសម្រេចរំលោភរបស់រដ្ឋាភិបាល យៀកណាមខាងត្បូងនោះ, សហគមន៍ខ្មែរនេះបានទទួលនូវការបង្ខំឲ្យចូលជាតិជាយៀកណាម ហើយគេពុំព្រមបើកឲ្យមានសិទ្ធិរក្សាទុកនូវទំនៀមទម្លាប់របស់ខ្លួន, ភាសារបស់ខ្លួន ព្រមទាំងទម្រង់ការនៃព្រះពុទ្ធសាសនា (ការហាមមិនឲ្យមានការសំដែងធម៌ទេសនាជាខ្មែរ, មិនឲ្យមានសៀវភៅធម៌ខ្មែរ ។ល។ ការរំលោភប៉ះពាល់ដល់សិទ្ធិដ៏ថ្លៃថ្នូរនៃមនុស្សទាំងនេះ កាន់តែមានច្រើនឡើងទៀតក្នុងឱកាសប៉ុន្មានខែក្រោយនេះ ដោយមានវិធានការជាពិសេសយ៉ាងសាហាវអាក្រក់បំផុតដែលមិនមែនជាអំពើ ផ្តាច់មុខតែខាងអ្នករដ្ឋការដ៏ត្រឹមត្រូវ តាមច្បាប់យៀកណាមខាងត្បូងតែប៉ុណ្ណោះទេ, ប៉ុន្តែគឺជាអំពើមកពីខាងពួកឧទ្ទាមដែលប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលនៅព្រៃនគរ ។ ជនរួមជាតិខ្មែរដ៏អភ័ព្វទាំងនេះជាច្រើនរយនាក់ បានប៉ុនប៉ងរត់ពីការជិះជាន់សង្កត់សង្កិននេះ ដើម្បីមករកជ្រកពួននៅក្នុងទឹកដីជាតិ ។ ជនរួមជាតិទាំងនេះបាន ត្រូវគេដេញតាម, ចាប់ឃុំឃាំង, ធ្វើទារុណកម្មដល់រូបកាយ, បាញ់រះសម្លាប់ចោល ។

ចំណែកខាងខ្លួនវិញ ប្រទេសកម្ពុជាក៏មានអានិកជនយៀកណាម រស់នៅក្នុងប្រទេសដោយសេរី ក្នុងចំណោមនៃប្រជាពលរដ្ឋរបស់យើងដែរ ហើយបានរក្សាទុកនូវសញ្ជាតិរបស់ខ្លួន, ភាសារបស់ខ្លួន, ទំនៀមទម្លាប់របស់ខ្លួន ។ លក្ខន្តិកៈនៃជនជាតិយៀកណាមទាំង ៤០០,០០០ នាក់ នេះគឺជាលក្ខន្តិកៈនៃជនជាតិបរទេសទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជា ទុកជាជនជាតិនៃប្រទេសខាងលិច ឬជនជាតិនៃប្រទេសអាស៊ីក៏ដោយ ។

យើងពុំអាចនៅជាគថ្លង់ ចំពោះសេចក្តីអំពាវនាវដ៏អស់សង្ឃឹមនៃជនរួមជាតិយើង ដែលរស់នៅក្នុងយៀកណាមខាងត្បូងនោះបានឡើយ ។ គឺហេតុនេះហើយ បានជាយើងបានប៉ុនប៉ងជាច្រើនលើកច្រើនគ្រាក្នុងកិច្ចចរចាគ្នាជាមួយរដ្ឋាភិបាលព្រៃនគរ ដើម្បីសុំឲ្យបានមានការសើរើរៀបចំលក្ខន្តិកៈរបស់ខ្លួននេះឡើងវិញ ឬក៏យ៉ាងហោចណាស់ ឲ្យបានដល់នូវការបន្ធូរបន្ថយខ្លះចំពោះជោគវាសនារបស់ខ្លួន ។ តែគេបានប្រឆាំងមិនព្រមទទួលតាមយើងសុំនេះទេ ។ យើងក៏បានសុំចំពោះទៅស្នងការដ្ឋានសម្រាប់អ្នកភៀសខ្លួន នៃអង្គការសហប្រជាជាតិទៀត ។ អ្នកធ្វើអង្កេតទាំងឡាយបានមក ហើយបានសួរចម្លើយដល់អ្នកដំណាងនៃអ្នកភៀសខ្លួន មកពីសហគមន៍ខ្មែរទាំងនោះ ហើយបានធ្វើសេចក្តីរាយការណ៍មួយ ។ តែគ្មានបានលទ្ធផលអ្វីសោះ ។

ការពុំព្រមរបស់រដ្ឋាភិបាលព្រៃនគរ ក្នុងការពិនិត្យរួមជាមួយយើង នូវបញ្ហាដែលកើតមានឡើងពីអានិកជនទាំង ៦០០,០០០ នាក់នេះ ពុំមែនមានដូចនៅក្នុងសាកលលោកនេះទេ ។ យើងមានឧទាហរណ៍ក្នុងរឿងនេះនៅប្រទេស "អូទ្រីស" នឹងនៅប្រទេស "អ៊ីតាលី" ដែលបានរិះរករួមជាមួយគ្នានូវការដោះស្រាយមួយចំពោះបញ្ហាប្រជាជននៅដំបន់ទន្លេ "អាឌីស" ខាងលើ ។ ប៉ុន្តែយៀកណាមខាងត្បូងគេសំអាងហេតុថា គេមិនមែនជាសមាជិកនៃ អ.ស.ប. ទេ ដើម្បីមិនព្រមជជែកពិភាក្សាអ្វីទាំងអស់ ជាហេតុធ្វើឲ្យឃើញនូវការគ្មានផលប្រយោជន៍ ដែលទុកប្រទេសខ្លះ និងប្រជាពលរដ្ឋខ្លះឲ្យនៅក្រៅអង្គការរបស់យើង ។ ការឥតផលប្រយោជន៍នេះបានកើតមានឡើងមួយចំណែកទៀត នៅក្នុងការលំបាកទាំងឡាយដែលអាចធ្វើឲ្យឃើញរូបរាងឡើង បើកាលគេគិតគូរនឹងយករឿងប្រទេសលាវទៅជូន អ.ស.ប. ដែលគ្មានទាំងយៀកណាមខាងជើង នឹងគ្មានទាំងប្រទេសចិនផងនោះ ពិនិត្យ ។

បញ្ហាអានិកជនខ្មែរ នៅយៀកណាមខាងត្បូងមិនមែនកើតមានតែម្នាក់ឯងក៏ទេដែរ នៅក្នុងសាកលលោក ។ គឺដោយហេតុនេះហើយដែលខ្ញុំជឿថា សហប្រជាជាតិត្រូវតែយកចិត្តជាចាំបាច់គិតដល់ ឲ្យបានខ្លាំងឡើងចំពោះកិច្ចការពារសិទ្ធិរបស់ក្រុមមនុស្ស ដែលត្រូវគេចងដៃចងជើងលែងឲ្យអ្នករំលោភជិះជាន់នោះ ៕

ជីវប្រវត្តិ

# ព្រះវីរៈធម្មាចារ្យ ព្រះមហា សឹន ថាន

## ប្រធានគណៈអាចារ្យ និងជាប្រធានសមណប្បាតុករ ខេត្តពលលាវ

ព្រះគ្រូធម្មាចារ្យ ព្រះមហា **សឹន ថាន** ប្រសូត្រនៅឆ្នាំ ច ព.ស. ២៤៧៧ គ.ស. ១៩៣៣ នៅតំបន់ឈើចុះ ភូមិព្រៃជាប់ ឃុំទឹកសាប ស្រុកជ្រោយញ ខេត្តពលលាវ ក្នុងត្រកូលកសិករមួយ ។

ឪពុកឈ្មោះ **សឹន ទេព** ម្ដាយឈ្មោះ **ត្រឹង ធីកែម**

កាលនៅពីកុមារភាព អាស្រ័យដោយគ្រួសារមានជីវភាពខ្វះខាតកុមារ **សឹន ថាន** បានរៀនត្រឹមតែប្រឡងជាប់ បឋមសិក្សាប័ត្រវៀតណាម ប៉ុណ្ណោះ ។ ក្រោយមកលោកតា **សឹន ទេព** និងលោកយាយ **ត្រឹង ធីកែម** ជាឪពុកនិងម្ដាយបានបញ្ជូនកុមារ **សឹន ថាន** ឲ្យមកនៅវត្តបម្រើព្រះសង្ឃ តាមការនិយមរបស់ប្រជាពលរដ្ឋខ្មែរផង និងដើម្បីរៀនអក្សរខ្មែរបន្តទៅទៀតផង។

លុះអាយុបាន ១៧ ឆ្នាំ ក្នុងឆ្នាំ ១៩៥០ យុវជន **សឹន ថាន** ក៏បានបួសជាសាមណេរ ក្នុង **វត្តទេពារាមព្រៃជាប់** ឃុំទឹកសាប ស្រុកជ្រោយញ ខេត្តពលលាវ ជាវត្តក្នុងភូមិកំណើត ។

ឆ្នាំ ១៩៥១-១៩៥៣ សាមណេរ **សឹន ថាន** បានចូលរៀនសាលាបាលីរង «ពុទ្ធិកបឋមសិក្សា» ក្នុងវត្តខាងលើ ក្នុងសំណាក់ព្រះមហាឧត្តមវិជ្ជា **ថាច់ ស៊ាម** និងលោកគ្រូ **ត្រឹង ខែន** ដោយបានប្រឡងជាប់វិញ្ញាបនប័ត្រពុទ្ធិក-បឋមសិក្សាសាលាបាលីទី ៣ ក្នុងឆ្នាំ ១៩៥៣ ។

ក្នុងឆ្នាំ ១៩៥៤ សាមណេរ **សឹន ថាន** បានឧប-សម្បទាជាភិក្ខុភាវៈក្នុងព័ទ្ធសីមា **វត្តទេពារាមព្រៃជាប់** ដោយ




មានព្រះតេជព្រះគុណព្រះបាទឡាត់ គណវិសាលញ្ញាណ **ត្រឹង យ៉ាន** ចៅអធិការវត្តជាព្រះឧបជ្ឈាយ៍ព្រះមហាឧត្តមវិជ្ជា **ថាច់ ស៊ាម** ជាញត្តិកម្មវាចារ្យ បានទទួលនាមបញ្ញត្តិថា **"ធម្មបាលោ"** ក្នុងគម្រប់អាយុ ២១ ឆ្នាំ ។

ក្នុងឆ្នាំដដែលនេះដែរ ភិក្ខុ **សឹន ថាន** ក៏បានទទួលបន្ទុកជាឧទ្ទេសាចារ្យ បង្រៀនសាលាបាលីនៅក្នុងវត្តនេះតាមការកំណត់របស់ពុទ្ធសាសនបណ្ឌិត្យរងនៅ ដែនដី-

កម្ពុជាក្រោម ។

ឆ្នាំ ១៩៥៥ ភិក្ខុ **សឺន ថាន** ត្រូវបានពុទ្ធសាសនបណ្ឌិត្យរងនៅ ដែនដីកម្ពុជាក្រោម ដែលពេលនោះគឺឧកញ៉ា **ឡឹម ឯម** ជាប្រធានបានបញ្ជូនមកបន្តការសិក្សាបាលីជាន់ខ្ពស់ ឬពុទ្ធិកវិទ្យាល័យ នៅទីក្រុងភ្នំពេញ ដោយបានមកស្នាក់នៅកុដិលេខ ៣២ **វត្តឧណ្ណាលោម** និងបន្តការសិក្សាសាលាបាលីជាន់ខ្ពស់ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត នារាជធានីភ្នំពេញ ។

ឆ្នាំ ១៩៥៩ ព្រះអង្គបានប្រឡងជាប់ ពុទ្ធិកមធ្យមសិក្សាប័ត្រ «សាលាបាលីឌីបល្លូម» ប្រកបដោយនិទ្ទេសល្អ និងបានទទួលនូវចំណាត់ថ្នាក់ដល់ទី "ព្រះមហា" ។

ឆ្នាំ ១៩៦០ ព្រះមហា **សឺន ថាន** បាននិមន្តទៅកាន់វត្តកំណើតវិញ ដើម្បីបន្តការបង្រៀនព្រះសង្ឃជំនាន់ក្រោយ និងពង្រីកការសិក្សា សាលាបាលី និង ធម្មវិន័យក្នុង **វត្តទេពារាមព្រៃជាប់** ដែលជាវត្តកំណើតរបស់ព្រះអង្គឲ្យកាន់តែមានការរីកចម្រើនថែមទៀត ។

សូមបញ្ជាក់ថា នាសម័យនោះ ទូទាំងខេត្តពលលាវទាំងមូល ព្រះថេរៈដែលបានទទួលចំណាត់ថ្នាក់ជាទី "មហា" មានតែ ៥ ព្រះអង្គប៉ុណ្ណោះគឺ ៖ ព្រះមហាឧត្តមវិជ្ជា **ថាច់ ស៊ាម** គង់នៅ **វត្តទេពារាមព្រៃជាប់** ឃុំទឹកសាប ស្រុកជ្រោយញ, ព្រះមហា **ហ៊ិញ កាម** គង់នៅ **វត្តឈូងធំ** ឃុំទឹកសាប ស្រុកជ្រោយញ, ព្រះមហា **សឺន ឈួន** គង់នៅ **វត្តដើមអម្ពិល** ឃុំព្រែកតាមុំ ស្រុកជ្រោយញ, ព្រះមហា **ថាច់ ធឿន** គង់នៅ **វត្តព្រែកជ្រៅ** ឃុំស្នែត ស្រុកពលលាវ និង ព្រះមហា **សឺន ថាន** នេះឯង ។

ក្នុងឋានៈជាអាចារ្យបង្រៀនផង និងជាព្រះពហុស្សូតស្គាំនៅក្នុងវត្តផង ព្រះអង្គតែងតែឆ្លៀតពេលអប់រំព្រះសង្ឃជាសមណសិស្ស និងពុទ្ធបរិស័ទទាំងអស់ ដោយបណ្តុះបណ្តាលគំនិតស្នេហាជាតិ ដល់ព្រះសង្ឃ និងពុទ្ធបរិស័ទជាញឹកញាប់ពិសេសគឺ ៖ ព្រះអង្គតែងតែរំឭក អំពីប្រវត្តិយួនយកក្បាលខ្មែរទៅដាំទឹកតែឲ្យលោកធំវា ក្នុងសម័យកំពុបតែអុង រឿងយួនចាក់សាំងដុតខ្មែរទាំងរស់ នៅតំបន់ ដាមតិញ, ដាមយើយ, ហ្វូថុង, យ៉ាវ៉ាយ, ផ្ទោអណ្តែត, កោះម្ហូត្ត និងទឹកខ្មៅ ជាដើម ។

ឆ្នាំ ១៩៦៨ ព្រះអង្គត្រូវបានទទួលការតែងតាំងជាលេខាធិការផ្ទាល់ ព្រះមេគណរងខេត្តពលលាវ ។

ឆ្នាំ ១៩៧១ បានចូលរួមក្នុងគណៈប្រតិភូព្រះសង្ឃខ្មែរកម្ពុជាក្រោម ដែលដឹកនាំដោយព្រះតេជព្រះគុណ ព្រះធម្មវិរិយោ **គឹម សាង** នាយកគណៈពុទ្ធសាសនាថេរវាទ មកចូលរួមពិធីបុណ្យរំលាយព្រះបរមសព សម្តេចព្រះសង្ឃរាជជោតិញ្ញាណោ **ជួន ណាត** នាទីក្រុងភ្នំពេញ «សាធារណរដ្ឋខ្មែរ» ។

ឆ្នាំ ១៩៧៣ គណៈមន្ត្រីសង្ឃខេត្តពលលាវ បានតែងតាំងព្រះអង្គ ជាប្រធានគណៈអាចារ្យខេត្ត ។

ក្នុងពេលផ្ទុះឡើងនូវ ព្រឹត្តិការណ៍បាតុកម្មរបស់ព្រះសង្ឃខ្មែរកម្ពុជាក្រោម នៅខាងមុខវិមានប្រធានាធិបតីយួនខាងត្បូង នាទីក្រុងព្រៃនគរ ដើម្បីទាមទារនាទីជាជនជាតិភាគតិច កាលពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ១៩៦៩ ។ ព្រះមហា **សឺន ថាន** គឺជាព្រះថេរៈមួយអង្គ ដែលមានការឈឺឆ្អាល ខ្នះខ្នែង និងគិតគូរពីការតស៊ូទាមទារនូវនាទីជាជនជាតិភាគតិចនេះយ៉ាងសកម្មបំផុត ។

ការនិមន្តបញ្ចុះបញ្ចូល ព្រះសង្ឃជាមន្ត្រីសង្ឃចៅអធិការ ភិក្ខុ សាមណេរ ដើម្បីធ្វើបាតុកម្មទូទាំងខេត្តពលលាវ គាំទ្រការតស៊ូរបស់ ព្រះសង្ឃខ្មែរកម្ពុជាក្រោម នាថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ១៩៦៩ នៅទីក្រុងព្រៃនគរនោះគឺ ព្រះមហា **សឺន ថាន** នេះឯង ។

ពេលនោះទើបមន្ត្រីសង្ឃ ក្នុងខេត្តពលលាវទាំងមូល ប្រគល់ភារកិច្ចប្រគេន ព្រះមហា **សឺន ថាន** ជាប្រធានសមណប្បាតុករ ដឹកនាំក្បួនបាតុកម្មមកតវ៉ាទាមទារនាទីជាជនជាតិភាគតិចនៅខាងមុខសាលាខេត្តចំនួន២ លើក។

ក្រៅពីការដឹកនាំព្រះសង្ឃ ធ្វើបាតុកម្មទាមទារនាទីជា ជនជាតិភាគតិច ព្រះមហា សឺន ថាន បានដឹកនាំព្រះសង្ឃ និងពុទ្ធបរិស័ទខ្មែរក្នុងខេត្ត ក្រោកឡើងប្រឆាំងនឹងរដ្ឋការយួនព្រៃនគរ លើការងារជាច្រើនទៀតដូចជា ៖ ប្រឆាំងការចាប់យុវជនខ្មែរ ទៅធ្វើទាហានបម្រើយួន, ប្រឆាំងរដ្ឋការយួន ដែលធ្វើការចាប់ឃុំ ឬឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរក្រោមដោយអយុត្តិធម៌, អំពើជ្រៀតជ្រែកចូលកិច្ចការព្រះសង្ឃខ្មែរក្រោម ពីសំណាក់រដ្ឋការយួន និងការបោះឆ្នោតដោយអយុត្តិធម៌ជាដើម ។

អាស្រ័យដោយមនសិការស្នេហាជាតិ និងវីរភាព

ក្លាហាន អង់អាច របស់ព្រះមហា **សឺន ថាន** ដូចពោលខាងលើនេះ ធ្វើឲ្យផែនការជាច្រើនដែលរដ្ឋការយួន ជាពិសេសអាជ្ញាធរយួនក្នុងខេត្តពលលាវ បានដាក់ចេញ ដើម្បីបំបាត់បំផុតពូជខ្មែរក្រោម ត្រូវរាំងស្ទះ ធ្វើឲ្យអាជ្ញាធរយួនមានការខឹងសម្បារយ៉ាងខ្លាំង ទើបអាជ្ញាធរយួនក្នុងខេត្តពលលាវ ដោយមានឈ្មោះវរសេនីយ៍ឯក **ហ៊ីញ ង៉ុកឌីប** (Huynh Ngoc Diep) ជាមេក្លោង តាមបញ្ជាដោយផ្ទាល់របស់រដ្ឋាភិបាលយួនព្រៃនគរ បានចេញបញ្ជាឲ្យអនុសេនីយ៍ឯក **ត្រឹង យ៉ីជឿង** (Tran Duy Chuong) ប្រធានមន្ទីរនគរ–បាលខេត្តពលលាវ ធ្វើឃាតព្រះមហា **សឺន ថាន** ដោយចោទប្រកាន់ព្រះអង្គថា ៖ តែងតែបំផុសព្រះសង្ឃធ្វើបាតុកម្ម ។

ព្រះមហា **សឺន ថាន** ត្រូវបានរដ្ឋការយួនធ្វើឃាតបានសម្រេចនៅថ្ងៃទី ៣ ខែមេសា ឆ្នាំ ១៩៧៣ ត្រូវនិងខែចេត្រ ឆ្នាំជូត ចត្វាស័ក ព.ស. ២៥១៧ វេលាម៉ោង ១៧ រសៀល នៅភូមិទឹកចែក ឃុំស្នែត ស្រុកពលលាវ ចម្ងាយពីភូមិព្រៃជាប់ប្រមាណ ៦ គ.ម និងឆ្ងាយពីទីរួមខេត្តពល–លាវ ប្រមាណ ៥ គ.ម ជាមួយនិងយុវជនម្នាក់ទៀតឈ្មោះ **លី ឧត្តម** ដែលត្រូវជាក្មួយរបស់ព្រះអង្គ ជាអ្នកបើកបរ ៕

***តាំង សារ:***

## ផលិតកម្មខ្មែរក្រោម

ដកស្រង់ចេញពី Vol. 1 នៃផលិតកម្មខ្មែរក្រោម

និពន្ធបទចម្រៀងដោយ ៖ *លោក ស័ក្តិ សាយឿន*

ច្រៀងដោយ ៖ *កញ្ញា ទូច ស៊ុននិច*

### បទចម្រៀង ៖

# ទន្លេគោក ខេត្ត ទឹកខ្មៅ

I–*អាល័យ អាឡោះ ស្រណោះស្រណោក បឹង*
*ទន្លេគោគខេត្តទឹកខ្មៅខាប់ ខ្មែរក្រោមទោរម្នេញ*
*យៀកមិញសម្លាប់ សម្លាប់កាប់ចាក់ដុតខ្មែរទាំង រស់ ។*

II–*កាលនៅ ពីក្មេង ខ្ញុំតែងបានស្តាប់ ម៉ែឪ*
*រាយរ៉ាប់ខ្ញុំចាំទាំងអស់ ក្នុងចិត្តចំណាំចាំមិន ភ្លេចសោះ*
*ជនប្រល័យពូជសាសន៍ ចោរយួនឈ្លានពាន ។*

R–*គ្រាំអើយ គ្រាំចិត្ត ឥតមានពេលល្ហែ គ្រាំចិត្ត*
*ព្រោះខ្មែរត្រូវស្លាប់រាប់លាន យៀកមិញកុងហ្វា*
*ជាយួនសាមាន្យ វាបានជិះជាន់ខ្មែរម្ចាស់ទឹកដី។*

III–*ស្រណោះជានិច្ច មិនភ្លេចឡើយណា ខ្មែរ*
*ក្រោមគ្រប់គ្នាសាមគ្គីព្រួតដៃ ក្រោកឡើងប្រ–*
*យុទ្ធតាមបែបផែនថ្មី ខ្មែរផុតទុក្ខភ័យ ជួបសុខ*
*សាន្តអើយ ៕* (ភ្លេងចប់ ច្រៀងវគ្គ R > III ម្តងទៀត)